ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៥ សរ.ណន

**សារាចរណែនាំ**

**ស្តីពី**

**ការពង្រឹងការអនុវត្តផែនការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់**

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និន្នាការនៃការផលិត ចរាចរ ដឹកជញ្ជូនគ្រឿងញៀនលើសកលលោកបន្តមានកំណើនឥតឈប់ឈរ ជាពិសេសការផលិតអាភៀនមួយភាគធំត្រូវបានប្តូរមកផលិតគ្រឿងញៀនសំយោគ ដែលប្រភេទសារធាតុញៀនទាំងនេះងាយស្រួលក្នុងការផលិត កែច្នៃ ងាយរកសារធាតុគីមីផ្សំ និងឧបករណ៍ផលិត ព្រមទាំងមិនរើសភូមិសាស្ត្រ ឬទីតាំងផលិត។ ការប្រែប្រួលនេះបានក្លាយជាកត្តាជំរុញធ្វើឱ្យទីផ្សារគ្រឿងញៀនសំយោគរីកកាន់តែធំទាំងក្នុង និងក្រៅតំបន់ ដែលក្នុងនោះព្រះរាជាណាចក្រកម្ពុជាក៏បាន និងកំពុងទទួលរងគ្រោះដោយសារឥទ្ធិពលនៃបទឧក្រិដ្ឋដែលមានលក្ខណៈជាសកលនេះដែរ។

តាមរយៈការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់របស់រាជរដ្ឋាភិបាលចំនួន ៥លើកជាបន្តបន្ទាប់ បណ្តាកងកម្លាំងអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធបានសហការគ្នាបង្កើតបានជាចលនាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនយ៉ាងសស្រាក់សស្រាំ និងទទួលបានលទ្ធផលជាផ្លែផ្កា។ ប៉ុន្តែប្រការដែលត្រូវបានកត់សម្គាល់ឃើញនោះគឺ សកម្មភាពលបលួចនាំចូល ដឹកជញ្ជូនគ្រឿងញៀនឆ្លងកាត់ ការលួចលាក់កែច្នៃសារធាតុញៀននៅតែកើតមានឡើងជាបន្តបន្ទាប់ និងមានរូបភាពកាន់តែធំ ហើយការជួញដូរ និងការប្រើប្រាស់សារធាតុញៀនបាន និងកំពុងរីករាលដាលដល់តំបន់ជនបទមួយចំនួន។

ឆ្លើយតបទៅនឹងសភាពការណ៍ខាងលើ និងក្នុងគោលបំណងធានាប្រសិទ្ធភាពអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក៏ដូចជាការបញ្ចៀសឱ្យបាននូវហានិភ័យដែលបណ្តាលមកពីគ្រឿងញៀន ព្រមទាំងដោះស្រាយនូវការព្រួយបារម្ភ និងការពារសុខុមាលភាពជូនប្រជាពលរដ្ឋ ធានាបាននូវស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

១.បន្តខិតខំចាត់តាំងអនុវត្តឱ្យបានម៉ឺងម៉ាត់តាមបទបញ្ជាលេខ ០១ប.ប ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

២.បង្កើនសកម្មភាពអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៥ ឱ្យបានសកម្មភាពផុលផុស និងត្រូវបន្តកសាងផែនការយុទ្ធនាការជាបន្តបន្ទាប់ប្រកបដោយនិរន្តរភាព។

៣.លើកកម្ពស់ស្មារតីផ្សព្វផ្សាយ អប់រំឱ្យបានទូលំទូលាយ ស៊ីជម្រៅ ចំគោលដៅ និងមុខសញ្ញា គ្រប់ទីកន្លែង ទាំងក្នុងសហគមន៍ ទាំងក្នុងស្ថាប័នរដ្ឋ ឯកជន និងក្នុងជួរកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយត្រូវអនុវត្តផ្សារភ្ជាប់ជាមួយខ្លឹមសារទិសស្លោក **«មីគុំ មួយរាយការណ៍»** គឺ : កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់ករណីបទល្មើសគ្រឿងញៀន។

៤.យកចិត្តទុកដាក់ចាត់វិធានការក្នុងការបង្ការ ទប់ស្កាត់ការនាំចូល ការដឹកជញ្ជូនឆ្លងកាត់ ការលួចលាក់កែច្នៃ-ផលិតសារធាតុញៀន និងការជួញដូរ-ប្រើប្រាស់សារធាតុញៀន ជាពិសេសនៅតាមគោលដៅនានា ដោយត្រូវ ៖

- បន្តពង្រឹងការគ្រប់គ្រង ត្រួតពិនិត្យការឆ្លងកាត់ព្រំដែន និងការដឹកជញ្ជូនទំនិញគ្រប់ប្រភេទ រួមទាំងបញ្ញើប្រៃសណីយ៍ ឱ្យបានហ្មត់ចត់ និងម៉ឺងម៉ាត់ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបការនាំចូលគ្រឿងញៀនខុសច្បាប់
- ជំរុញការស្រាវជ្រាវ ស៊ើបអង្កេតកៅខ្សែរយៈបណ្តាញមេក្លោងជួញដូរសារធាតុញៀន និងធ្វើការបង្ក្រាបឱ្យដល់ឫសគល់ ព្រមទាំងបន្តពន្លាតនីតិវិធីឈានដល់ការបង្ក្រាបបទល្មើសសម្អាតប្រាក់ ដែលជាផលនៃបទល្មើសគ្រឿងញៀន ដោយត្រូវពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ
- អនុវត្តព្រមៗគ្នារវាងវិធានការរដ្ឋបាល និងវិធានការច្បាប់ ធ្វើការបង្ក្រាបដូចភ្លៀងរលឹមសំដៅលុបបំបាត់ការលួចលាក់កែច្នៃ ការជួញដូរ ប្រើប្រាស់សារធាតុញៀន ជាពិសេសនៅតាមគោលដៅដែលងាយកើតមានបទល្មើសគ្រឿងញៀន។

៥.ត្រូវពង្រឹងវិធានការគ្រប់គ្រង ត្រួតពិនិត្យការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុតទៅតាមវិធានបច្ចេកទេស និងត្រូវដកពិសោធន៍ ធ្វើបច្ចុប្បន្នភាពជាប្រចាំ សំដៅបង្ការមិនឱ្យសារធាតុគីមីផ្សំធ្លាក់ក្នុងដៃឧក្រិដ្ឋជនយកទៅកែច្នៃធ្វើជាសារធាតុញៀនជាដាច់ខាត។

៦.លើកកម្ពស់គុណភាពក្នុងការអនុវត្តវិធានការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មដោយខិតខំឱ្យអស់ពីលទ្ធភាពលើកកម្ពស់សមត្ថភាពព្យាបាល ស្តារនីតិសម្បទា និងរៀបចំ

បន្ថែមនូវមណ្ឌលបណ្តោះអាសន្ននៅតាមរាជធានី ខេត្ត ស្របតាមភូមិសាស្ត្រ និងសំណូមពរជាក់ស្តែង។

៧.លើកកម្ពស់គុណភាព សមត្ថភាពមន្ត្រីអនុវត្តច្បាប់ តាមរយៈការបណ្តុះបណ្តាលជំនាញប្រតិបត្តិការ និងចំណេះដឹងផ្នែកច្បាប់។ ទន្ទឹមនេះ ត្រូវពង្រឹងការអនុវត្តវិន័យ សីលធម៌ មនសិការវិជ្ជាជីវៈដល់កងកម្លាំងអនុវត្តច្បាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យបានល្អប្រសើរ ព្រមទាំងបន្តការគាំទ្រ សរសើរជូនរង្វាន់ លើកទឹកចិត្តដល់អង្គភាព និងមន្ត្រីដែលមានស្នាដៃ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួង-ស្ថាប័នពាក់ព័ន្ធ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលើកកម្ពស់ស្មារតីទទួលខុសត្រូវក្នុងការដឹកនាំចាត់តាំងអនុវត្តសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ១កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ